ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក

CAMPU LONPAC INSURANCE 柬埔寨大众伦平保险

# យើងខ្ញុំធានារ៉ាប់រងលោកអ្នក ក្នុងប្រទេសកម្ពុជា

## អត្ថប្រយោជន៍ទាំងអស់នៃកិច្ចសន្យាធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល

ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងសេវាកម្មរបស់ក្រុមហ៊ុនយើងខ្ញុំ សូមមេត្តាសរសេរលិខិតមកក្រុមទទួលពាក្យបណ្តឹងរបស់យើងខ្ញុំ :

| | | |
|---|---|---|
| អាសយដ្ឋានទំនាក់ទំនង | : | **ក្រុមហ៊ុនធានារ៉ាប់រង កម្ពុលូនប៉ាក ភីអិលស៊ី**<br>ជាន់ទី៧ នៃអគារកម្ពុបែ៊ង<br>ផ្ទះលេខ ២៣ ផ្លូវ ១១៤<br>សង្កាត់ផ្សារថ្មី ២<br>ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា<br>ប្រអប់សំបុត្រ ១៩៥៦ |
| លេខទូរស័ព្ទ | : | + ៨៥៥ ២៣ ៩៦៦ ៩៦៦ / ៩៩៨ ២០០ / ៩៨៦ ២៧៩ |
| លេខទូរសារ | : | + ៨៥៥ ២៣ ៩៨៦ ៣០៨ / ២៧៣ |
| អ៊ីមែល | : | complaint@campulonpac.com.kh |
| គេហទំព័រ | : | www.campulonpac.com.kh |

**ក្នុងករណីមានឧប្បត្តិហេតុកើតឡើង**

**លេខទូរស័ព្ទប្រចាំការ២៤ម៉ោង**

+ ៨៥៥ ១៦ ៨១០ ៩៩៩ / ៨២០ ៩៩៩

+ ៨៥៥ ១៧ ៧៩៩ ៩០២ / ៧៩៩ ៩០៣

អ៊ីមែល : claims@campulonpac.com.kh

<u>សំគាល់:</u>

ក្នុងករណីមានវិវាទកើតឡើង ឬការខុសឆ្គងអត្ថន័យណាមួយនៅក្នុងកិច្ចសន្យាធានារ៉ាប់រងជាភាសាខ្មែរ នោះក្រុមហ៊ុនធានារ៉ាប់រងយើងខ្ញុំនឹងយកកិច្ចសន្យាធានារ៉ាប់រងជាភាសាអង់គ្លេសជាសំអាង ។
យើងខ្ញុំសូមស្នើជាពិសេសថា សូមលោកអ្នកអានកិច្ចសន្យាធានារ៉ាប់រងនេះអោយបានហ្មត់ចត់ និងផ្ញើត្រឡប់មកកាន់ក្រុមហ៊ុនយើងខ្ញុំវិញភ្លាម ប្រសិនបើមានភាពចាំបាច់ត្រូវកែតម្រូវ ។

## អត្ថប្រយោជន៍ទាំងអស់នៃកិច្ចសន្យាធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល

**ដោយហេតុថា** បុគ្គលដែលត្រូវបានធានារ៉ាប់រង ដូចមានឈ្មោះនៅក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យា បានធ្វើសំណើ និងសេចក្តីប្រកាស ជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុនធានារ៉ាប់រង កម្ពុជ្ញបញ៉ា ភីអិលស៊ី (តទៅនេះ ហៅកាត់ថា "ក្រុមហ៊ុន") ដែលត្រូវធ្វើជាមូលដ្ឋាននៃកិច្ចសន្យានេះ និងត្រូវចាត់ទុកថាត្រូវរួមបញ្ចូលក្នុងកិច្ចសន្យានេះ ព្រមទាំងបានបង់ ឬបានយល់ព្រមបង់ថ្លៃបុព្វលាភធានារ៉ាប់រង ដូចមានចែងនៅក្នុងឧបសម្ព័ន្ធជាថ្នូរនឹងការធានារ៉ាប់រង ដូចមានចែងនៅក្នុងកិច្ចសន្យានេះ ។

**ដោយហេតុនេះ កិច្ចសន្យានេះផ្តល់នូវសក្ខីកម្មដែលបញ្ជាក់ថា** ប្រសិនបើនៅពេលណាមួយក្នុងអំឡុងរយៈពេលនៃការធានារ៉ាប់រង ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យា ឬក្នុងអំឡុងរយៈពេលបន្ថែមណាមួយដែលសម្រាប់រយៈពេលនេះ ក្រុមហ៊ុនអាចទទួលយកការបង់បុព្វលាភធានារ៉ាប់រងសម្រាប់ការបន្តកិច្ចសន្យានេះ បុគ្គលដែលត្រូវបានធានារ៉ាប់រងទទួលរងរបួសលើរាងកាយដែលបង្កឡើងទាំងស្រុង និងដោយផ្ទាល់ដោយសារកត្តាគ្រោះថ្នាក់ពីខាងក្រៅ និងដែលមើលឃើញនឹងភ្នែក និងជាមូលហេតុតែមួយគត់ និងដោយផ្ទាល់នៃការស្លាប់ ឬពិការភាពរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដូចត្រូវបានកំណត់នៅក្នុងកិច្ចសន្យានេះ **ពេលនោះ**ក្រុមហ៊ុននឹងបង់ប្រាក់ជូនបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬតំណាងផ្ទាល់ខ្លួនដែលមានការអនុញ្ញាតពីបុគ្គលដែលត្រូវបានធានារ៉ាប់រង ក្នុងករណីបុគ្គលដែលត្រូវបានធានារ៉ាប់រងនោះស្លាប់ នូវទឹកប្រាក់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ។

**កិច្ចសន្យានេះ ជានិច្ចកាលចែងថា :**

១. គ្មានសំណងណាមួយ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនឹងត្រូវទូទាត់ឡើយ :

(ក) នៅក្នុងចំណុច **ក** ដល់ចំណុច **ខ** លើកលែងតែការស្លាប់ ឬការបាត់បង់កើតឡើងក្នុងរយៈពេល ៣៦៥ ថ្ងៃ ក្រោយកាលបរិច្ឆេទរងរបួសលើរាងកាយ ។

(ខ) រហូតដល់ពេលដែលទឹកប្រាក់សរុបនៃសំណងត្រូវបានកំណត់ និងឯកភាព ។

២. ទាក់ទងទៅនឹងទឹកប្រាក់ដែលត្រូវបង់យោងតាមចំណុច **ខ** ទឹកប្រាក់សំណងអតិបរមាមិនត្រូវលើសពី ១០០% នៃទឹកប្រាក់ដើម យោងតាមចំណុច **ក** ឡើយ ហើយក្នុងករណីដាច់ម្រាមដៃនៅដៃម្ខាង នោះទឹកប្រាក់សំណងអតិបរមាមិនត្រូវលើសពីចំនួនទឹកប្រាក់ដែលត្រូវបង់សម្រាប់ការដាច់ដៃម្ខាងឡើយ ។

៣. បុគ្គលដែលត្រូវបានធានារ៉ាប់រងមិនមានសិទ្ធិទទួលបានសំណង តាមចំណុចដែលមានចែងនៅក្នុងឧបសម្ព័ន្ធលើសពីមួយឡើយ ទាក់ទងនឹងគ្រោះថ្នាក់មួយលើក ។

៤. ក្រុមហ៊ុននឹងមិនទទួលខុសត្រូវលើការបង់ប្រាក់បន្ថែមណាមួយឡើយ យោងតាមកិច្ចសន្យានេះ បន្ទាប់ពីការទាមទារសំណងយោងតាមចំណុច **ក** ឬចំណុច **ខ** ត្រូវបានទទួលយក និងដល់ពេលត្រូវបង់ ។

៥. កិច្ចសន្យានេះ**នឹងមិនធានាទៅលើ** ការស្លាប់ ការបាត់បង់ ឬពិការភាព ដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬប្រយោល :

(ក) នៅក្នុងពេលដែលបុគ្គលដែលត្រូវបានធានារ៉ាប់រងកំពុងប្រើប្រាស់ម៉ាស៊ីនជាងឈើដែលដើរដោយកម្លាំង មេកានិក ឬក៏កំពុងជិះទោចក្រយានយន្ត (ទោះបីជាជិះក្នុងឋានៈជាអ្នកដំណើរ ឬអ្នកបើកបរក៏ដោយ និងទោះបីជាមាន ឬគ្មានរ៉ឺម៉កចំហៀងក៏ដោយ) ឬកំពុងចូលរួមលេងកីឡាអាជីព កីឡាបរបាញ់ កីឡាឡើងភ្នំ កីឡាជិះស្គីលើទឹក កីឡាជិះរទេះគោ កីឡាជិះគោរំអិល កីឡាប្រណាំងប្រភេទផ្សេងពីការរត់ប្រណាំង កីឡាប្រដាល់ កីឡាកាស កីឡាប្រយុទ្ធមិនប្រើអាវុធគ្រប់ប្រភេទ កីឡារជូរងារ កីឡាហុកឃីលើទឹកកក កីឡាជិះសេះលេងបាល់ សកម្មភាពក្រោមទឹកដែលតម្រូវអោយប្រើប្រាស់ឧបករណ៍ដកដង្ហើម កីឡាជិះស្គី លោតលើទឹក កីឡាលោតឆ័ត្រយោង កីឡាជិះយានហោះគ្មានម៉ាស៊ីន កីឡាជិះសេះផ្លោះរបង កីឡាលោតខ្សែយឺត និងកីឡា ឬសកម្មភាពមានគ្រោះថ្នាក់ផ្សេងទៀត ។

(ខ) ដោយជំងឺឆ្កួតជ្រូក ឬដោយជំងឺក្លួន ជំងឺគ្រប់ប្រភេទ ជំងឺកាមរោគ បណ្តុំរោគសញ្ញាប្រព័ន្ធភាពស៊ាំចុះខ្សោយ (ជំងឺអេដស៍) ឬបណ្តុំរោគសញ្ញាសាំញ៉ាំទាក់ទងនឹងជំងឺអេដស៍ (ARC) ទោះបីជាបណ្តុំរោគសញ្ញានេះត្រូវបានរកឃើញ ឬត្រូវបានអោយឈ្មោះក៏ដោយ អំណាចតុលាការ អំពើខុសច្បាប់ដែលប្រព្រឹត្តដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬការដែលបុគ្គលដែលត្រូវបានធានារ៉ាប់រង ប្រឈមមុខដោយចេតនាទៅនឹងគ្រោះថ្នាក់ដែលមិនចាំបាច់ លើកលែងតែក្នុងការព្យាយាមជួយសង្គ្រោះជីវិតមនុស្ស ។

(គ) នៅពេលដែលបុគ្គលដែលត្រូវបានធានារ៉ាប់រង មានផ្លូវចិត្តមិនរឹងប៉ឹង ។

(ឃ) នៅពេលដែលបុគ្គលដែលត្រូវបានធានារ៉ាប់រងកំពុងបម្រើការងារនៅក្នុងកងកម្លាំងប្រដាប់អាវុធនៃប្រទេស ឬអាជ្ញាធរអន្តរជាតិណាមួយទោះបីជាក្នុងពេលមានសន្តិភាព ឬសង្គ្រាមក៏ដោយ ហើយក្នុងករណីនេះ ក្រុមហ៊ុនត្រូវធ្វើការសងថ្លៃបុព្វលាភធានារ៉ាប់រងតាមសមាមាត្រទៅនឹងរយៈពេលនៃការបម្រើការងារនេះ បន្ទាប់ពីទទួលបានពាក្យសុំរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

៦. កិច្ចសន្យានេះមិនធានាទៅលើ ការស្លាប់ ការបាត់បង់ ឬពិការភាព ដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬប្រយោលដោយសារ :

(ក) សង្គ្រាម ការឈ្លានពាន សកម្មភាពរបស់សត្រូវបរទេស អរិភាព (ទោះបីជាសង្គ្រាមត្រូវបាន ឬមិនត្រូវបានប្រកាសក្តី) សង្គ្រាមស៊ីវិល អំពើឧទ្ទាម បដិវត្តន៍ ការបះបោរ ការដណ្តើមអំណាចដោយយោធា ឬខុសច្បាប់ ហើយក្នុងករណីមានការទាមទារសំណង បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវផ្តល់ភស្តុតាងបង្ហាញថា ការទាមទារនោះបានកើតឡើងដោយមិនអាស្រ័យ និងមិនទាក់ទង ទោះជាដោយប្រការណាមួយក៏ដោយ ឬត្រូវបានបង្កឡើង ឬចូលចំណែកបង្កហេតុឡើង ឬបណ្តាលមកពីការកើតឡើងនៃហេតុការណ៍ទាំងនេះណាមួយ ឬផលវិបាកនៃហេតុការណ៍ទាំងនេះ ហើយប្រសិនបើគ្មានភស្តុតាងនេះទេ ក្រុមហ៊ុននឹងមិនទទួលខុសត្រូវលើការសងប្រាក់ទាក់ទងនឹងការទាមទារនេះឡើយ ។

(ខ) សារធាតុអាវុធនុយក្លេអ៊ែរ ឬចូលរួមចំណែកបង្កហេតុឡើង ឬកើតឡើងដោយសារវិទ្យុសកម្មអ៊ីយ៉ុង ឬការបំពុលដោយសកម្មភាពវិទ្យុសកម្មដែលភាយចេញពីសំណល់នុយក្លេអ៊ែរ ពីចំហេះឥន្ធនៈនុយក្លេអ៊ែរ ។ សម្រាប់តែគោលបំណងនៃការលើកលែងនេះប៉ុណ្ណោះ ចំហេះត្រូវរាប់បញ្ចូលនូវដំណើរការដោយខ្លួនឯងនៃការបំបែកអាតូមនុយក្លេអ៊ែរ ។

(គ) បុគ្គលដែលត្រូវបានធានារ៉ាប់រងកំពុងធ្វើដំណើរតាមយន្តហោះ លើកលែងតែក្នុងឋានៈជាអ្នកដំណើរនៅក្នុងយន្តហោះដឹកអ្នកដំណើរដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ប៉ុន្តែមិនមែនក្នុងឋានៈជាសមាជិកនៃក្រុមអាកាសយានិក ឬ សម្រាប់គោលបំណងធ្វើកិច្ចការជំនួញ ឬប្រតិបត្តិការបច្ចេកទេសនៅក្នុងយន្តហោះនោះទេ ។

(ឃ) ការបង្ករបួសដោយខ្លួនឯង ការធ្វើអត្តឃាត ឬការប៉ុនប៉ងធ្វើអត្តឃាត (ទោះបីជាបទឧក្រិដ្ឋ ឬមិនមែនបទឧក្រិដ្ឋក្តី) ការញុះញង់អោយមានអំពើហិង្សា គ្រឿងស្រវឹង គ្រឿងញៀន ឬជំងឺវិកលចរិក ។

(ង) នៅពេលដែលបុគ្គលដែលត្រូវបានធានារ៉ាប់រងជាស្ត្រីមានគភ៌ ការសម្រាលកូន ឬការប្រសូតកូន ។

## ៧. ខលើកលែងចំពោះអំពើភេរវកម្ម (គ្របដណ្តប់នៅទូទាំងពិភពលោក)

ការធានារ៉ាប់រងដែលត្រូវបានចែងនៅក្នុងកិច្ចសន្យានេះ មិនអនុវត្តចំពោះករណីដូចខាងក្រោមនេះទេ :

រាល់ការបាត់បង់ ថ្លៃចំណាយ ឬការចំណាយដែលកើតឡើង ឬទាក់ទងទៅនឹង "សកម្មភាពភេរវកម្ម" ទោះជាដោយផ្ទាល់ ឬប្រយោលក្តី ដែលត្រូវបានកំណត់នៅក្នុងកិច្ចសន្យានេះ ។ ការលើកលែងនេះត្រូវយកមកអនុវត្តដោយមិនគិតអំពីមូលហេតុ ឬហេតុការណ៍ផ្សេងទៀត ដែលចូលរួមចំណែកក្នុងពេលជាមួយគ្នា ឬមុនក្រោយគ្នា ទោះជាដោយប្រការណាក៏ដោយ ធ្វើអោយមានការបាត់បង់ ថ្លៃចំណាយ ឬការចំណាយ ។ សម្រាប់គោលបំណងនៃការលើកលែងនេះ :

ក. "សកម្មភាពភេរវកម្ម" សំដៅដល់រាល់ទង្វើខុសច្បាប់មានការគ្រោងទុកជាមុនដែល :

១. ត្រូវបានប្រកាសដោយមន្ត្រីរដ្ឋាភិបាលមានសមត្ថកិច្ចថាជា ឬជាប់ពាក់ព័ន្ធជាមួយនឹងភេរវកម្ម សកម្មភាពភេរវករ ឬអំពើភេរវកម្ម ឬ

២. រួមបញ្ចូល ជាប់ពាក់ព័ន្ធជាមួយ ឬទាក់ទងជាមួយនឹងការប្រើប្រាស់ ឬការគំរាមប្រើប្រាស់កម្លាំង អំពើហិង្សា ឬការបៀតបៀនទៅលើបុគ្គល ទ្រព្យសម្បត្តិរូបី ឬអរូបី បរិស្ថាន ឬធនធានធម្មជាតិ នៅពេលដែលអំពើនោះត្រូវបានគ្រោងទុកជាមុនទាំងស្រុង ឬមួយចំណែកដើម្បី :

(ក) ធ្វើការផ្សព្វផ្សាយ ឬពង្រីកនូវបុព្វហេតុ ឬទិសដៅនយោបាយ មនោគមវិជ្ជា ទស្សនវិជ្ជា ពូជសាសន៍ ជាតិពន្ធុ សង្គម ឬសាសនារបស់ឧក្រិដ្ឋជន ឬអង្គការ សមាគម ឬក្រុមដែលពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋជន

(ខ) ធ្វើអោយប៉ះពាល់ បង្អាក់ ឬជ្រៀតជ្រែកចូលក្នុងប្រតិបត្តិការ សកម្មភាព ឬគោលនយោបាយដែលទាក់ទងជាមួយនឹងរដ្ឋាភិបាល

(គ) សម្លុត ដាក់សម្ពាធ ឬបំភិតបំភ័យសាធារណជនទូទៅ ឬផ្នែកណាមួយនៃសាធារណជន ឬ

(ឃ) បង្អាក់ ឬជ្រៀតជ្រែកចូលក្នុងសេដ្ឋកិច្ចជាតិ ឬផ្នែកណាមួយនៃសេដ្ឋកិច្ចជាតិ ឬ

៣. រួមបញ្ចូល ជាប់ពាក់ព័ន្ធ ឬមានទំនាក់ទំនងទាំងស្រុង ឬដោយផ្នែកជាមួយនឹងសកម្មភាពដូចខាងក្រោម ឬគំរាមប្រព្រឹត្តនូវសកម្មភាពទាំងនេះ :

(ក) ការប្លន់យន្តហោះ ឬការបំផ្លិចបំផ្លាញមធ្យោបាយដឹកជញ្ជូន ឬយានជំនិះក្នុងទម្រង់ណាមួយរួមមានជាអាទិ៍ យានអវកាស ផ្កាយរណប យន្តហោះ រថភ្លើង កប៉ាល់ ឬយានយន្ត

(ខ) ការចាប់ចំណាប់ខ្មាំង ឬការចាប់ជំរិត

(គ) ការប្រើប្រាស់ភ្នាក់ងារ សារធាតុ ឧបករណ៍ ឬអាវុធជីវសាស្ត្រ គីមី វិទ្យុសកម្ម ឬនុយក្លេអ៊ែរ

(ឃ) ការប្រើប្រាស់គ្រាប់បែក ឧបករណ៍បង្កអោយមានចំហេះ ជាតិផ្ទុះ ឬកាំភ្លើង

(ង) ការរំខាន ឬការបង្អាក់នូវសេវា និងប្រព័ន្ធសាធារណៈ ឬពាណិជ្ជកម្មមូលដ្ឋានរួមមានជាអាទិ៍ សេវា ឬប្រព័ន្ធដូចតទៅ : អគ្គិសនី ឧស្ម័នធម្មជាតិ ថាមពល ប្រៃសណីយ៍ គមនាគមន៍ ទូរគមនាគមន៍ ព័ត៌មាន ការដឹកជញ្ជូនសាធារណៈ ទឹក ប្រេងឥន្ធនៈ លូទឹកស្អុយ និងការប្រមូលសំរាម

(ច) ការបង្ករបួសស្នាម ឬការលួចធ្វើឃាតមន្ត្រីរដ្ឋាភិបាល ឬបុគ្គលិករបស់រដ្ឋាភិបាល ដែលជាប់ឆ្នោត ឬដែលត្រូវបានចាត់តាំង

(ឆ) ការចូលកាន់កាប់ ការរាំងខ្ទប់ ការរំខាន ការបង្អាក់ ឬការធ្វើអោយខូចខាតដល់អគារ ស្ថាប័ន ពិធី ព្រឹត្តិការណ៍ ទ្រព្យសម្បត្តិរូបី ឬអរូបី ឬទ្រព្យសម្បត្តិដទៃទៀតរបស់រដ្ឋាភិបាល ឬ

(ជ) ការចូលកាន់កាប់ ការរាំងខ្ទប់ ការរំខាន ការង្អាក់ ឬការធ្វើអោយខូចខាតដល់រូងផ្លូវក្រោមដី ផ្លូវថ្នល់ ដងវិថី មហាវិថី ឬទីកន្លែងដឹកជញ្ជូនសាធារណៈផ្សេងទៀត ។

ខ. រាល់សកម្មភាពដែលត្រូវបានរៀបរាប់នៅក្នុងចំណុច ក(៣) ខាងលើ ត្រូវបានចាត់ទុកថាជាសកម្មភាពភេរវករ លើកលែងតែក្នុងករណីដែលបុគ្គលដែលត្រូវបានធានារ៉ាប់រង អាចបង្ហាញយ៉ាងច្បាស់ដល់ក្រុមហ៊ុនថា សកម្មភាពខាងលើ ឬការគំរាមប្រព្រឹត្តសកម្មភាពទាំងនោះ ត្រូវបានបង្កឡើងទាំងស្រុងដោយសារគោលដៅផ្ទាល់ខ្លួនរបស់ឧក្រិដ្ឋជនដែលមិនមានការទាក់ទងទាំងស្រុង ឬដោយផ្អែកទៅនឹងចេតនាណាមួយដើម្បី :

១. ធ្វើការផ្សព្វផ្សាយ ឬពង្រីកនូវបុព្វហេតុ ឬទិសដៅនយោបាយ មនោគមវិជ្ជា ទស្សនវិជ្ជា ពូជសាសន៍ ជាតិពន្ធុ សង្គម ឬសាសនារបស់ឧក្រិដ្ឋជន ឬអង្គការ សមាគម ឬក្រុមដែលពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋជន

២. ធ្វើអោយប៉ះពាល់ បង្អាក់ ឬជ្រៀតជ្រែកចូលក្នុងប្រតិបត្តិការ សកម្មភាព ឬគោលនយោបាយ ដែលទាក់ទងជាមួយនឹងរដ្ឋាភិបាល

៣. សម្លុត ដាក់សម្ពាធ ឬបំភិតបំភ័យសាធារណជនទូទៅ ឬផ្នែកណាមួយនៃសាធារណជន ឬ

៤. បង្អាក់ ឬជ្រៀតជ្រែកចូលក្នុងសេដ្ឋកិច្ចជាតិ ឬសេដ្ឋកិច្ច ឬផ្នែកណាមួយនៃសេដ្ឋកិច្ចជាតិ ។

(NMA 2919)

# សំណង

**ទឹកប្រាក់ដែលត្រូវបានធានា**

**ចំណុច ក. គ្រោះថ្នាក់ដែលបណ្តាលអោយបាត់បង់ជីវិត**........................................................................... ទឹកប្រាក់មានរៀបរាប់ នៅក្នុង**ឧបសម្ព័ន្ធ**

**ចំណុច ខ. ពិការភាពអចិន្ត្រៃយ៍ទាំងស្រុង/ដោយផ្នែក**

| | |
|---|---|
| បាត់បង់អវយវៈពីរ | ] |
| ពិការដៃទាំងពីរ ឬម្រាមដៃទាំងអស់ និងមេដៃទាំងពីរ | ] |
| ភ្នែកទាំងពីរងងឹតទាំងស្រុង | ] |
| ពិការទាំងស្រុង | ] |
| របួសដែលបណ្តាលអោយដេកលើគ្រែជាអចិន្ត្រៃយ៍ | ] |
| របួសដទៃទៀតដែលនាំអោយពិការជាអចិន្ត្រៃយ៍ទាំងស្រុង | ] |
| ដាច់ដៃត្រឹមស្មា | ] |
| ដាច់ដៃនៅចន្លោះស្មា និងកែងដៃ | ] |
| ដាច់ដៃត្រឹមកែងដៃ | ] ១០០% នៃចំណុច ក |
| ដាច់ដៃនៅចន្លោះកែងដៃ និងកដៃ | ] |
| ដាច់ដៃត្រឹមកដៃ | ] |
| ដាច់ជើង - ត្រឹមត្រគាក | ] |
| ចន្លោះជង្គង់ និងត្រគាក | ] |
| ខាងក្រោមជង្គង់ | ] |
| ងងឹតភ្នែក - មើលមិនឃើញទាំងស្រុង | ] |
| បាត់បង់ចក្ខុប្រសាទ | ] |
| ងងឹតភ្នែកតែដឹងពន្លឺ........................................ | ៥០% |
| បាត់បង់កែវភ្នែក........................................ | ៥០% |
| ដាច់ម្រាមដៃបួន និងមេដៃម្ខាង........................ | ៥០% |
| ដាច់ម្រាមដៃបួន........................................ | ៤០% |

**ចំណុច ខ. (ត)**

| | | |
|---|---|---|
| ដាច់មេដៃ | - ពីរថ្នាំងដៃ | ២៥% |
| | - មួយថ្នាំងដៃ | ១០% |
| ដាច់ចង្អុលដៃ | - បីថ្នាំងដៃ | ១០% |
| | - ពីរថ្នាំងដៃ | ៨% |
| | - មួយថ្នាំងដៃ | ៤% |
| ដាច់ម្រាមកណ្តាល | - បីថ្នាំងដៃ | ៦% |
| | - ពីរថ្នាំងដៃ | ៤% |
| | - មួយថ្នាំងដៃ | ២% |
| ដាច់នាងដៃ | - បីថ្នាំងដៃ | ៥% |
| | - ពីរថ្នាំងដៃ | ៤% |
| | - មួយថ្នាំងដៃ | ២% |
| ដាច់កូនដៃ | - បីថ្នាំងដៃ | ៤% |
| | - ពីរថ្នាំងដៃ | ៣% |
| | - មួយថ្នាំងដៃ | ២% |
| បាត់បង់ឆ្អឹងប្រអប់ដៃ | - ទី១ ឬ ២ (បន្ថែម) | ៣% |
| | - ទី៣, ៤ ឬ ៥ (បន្ថែម) | ២% |
| ដាច់ម្រាមជើង | - ទាំងអស់ | ១៥% |
| | - មេជើង, ពីរថ្នាំង | ៥% |
| | - មេជើង, មួយថ្នាំង | ២% |
| | - ម្រាមផ្សេងពីមេជើង ប្រសិនបើដាច់លើសពីមួយ ក្នុងម្រាមមួយ | ១% |
| ថ្លង់ | - ត្រចៀកទាំងពីរ | ៧៥% |
| | - ត្រចៀកម្ខាង | ១៥% |

ការបាត់បង់នូវការប្រើប្រាស់អវយវៈទាំងស្រុងជាអចិន្ត្រៃយ៍ ត្រូវចាត់ទុកថាជាការបាត់បង់អវយវៈមួយនោះ ។ ប្រសិនបើរបួសមិនត្រូវបានបញ្ជាក់ដូចតារាងខាងលើ ក្រុមហ៊ុននឹងធ្វើការជ្រើសរើសយកនូវភាគរយណាមួយនៃពិការភាព ដែលក្រុមហ៊ុនយល់ថាត្រូវគ្នាទៅនឹងមាត្រដ្ឋានខាងលើ ។

ចំនួនសរុបនៃភាគរយទាំងអស់ដែលត្រូវសងសម្រាប់គ្រោះថ្នាក់មួយលើកនោះមិនត្រូវលើសពី ១០០% ឡើយ ។ ក្នុងករណីដែលចំនួនសរុប ១០០% ត្រូវបានសង ការធានារ៉ាប់រងទាំងអស់នៅក្នុងកិច្ចសន្យានេះនឹងអស់សុពលភាពភ្លាមៗ ។ ការបាត់បង់ផ្សេងទៀតទាំងអស់ដែលតិចជាង ១០០% ប្រសិនបើត្រូវបានសងរួចហើយ ត្រូវដកចេញពីការធានារ៉ាប់រងត្រឹមចំនួននោះ ដោយគិតចាប់ពីកាលបរិច្ឆេទមានគ្រោះថ្នាក់រហូតដល់ពេលចប់កិច្ចសន្យានេះ ។

នៅពេលដែលការទាមទារសំណង និង/ឬការបង់ប្រាក់ត្រូវបានធ្វើឡើងសម្រាប់គ្រោះថ្នាក់ណាមួយដល់បុគ្គលដែលត្រូវបានធានារ៉ាប់រង ក្រុមហ៊ុននឹងមិនធ្វើការបង់ប្រាក់ផ្សេងទៀតទាក់ទងនឹងរបួសដដែលរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងនោះទេ ។

**ចំណុច គ. សំណងលើថ្លៃព្យាបាលរបួសដែលបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុ** (តាមការជ្រើសរើស) ចំនួនទឹកប្រាក់មានរៀបរាប់នៅក្នុងឧបសម្ព័ន្ធសំណងនេះនឹងធ្វើការទូទាត់ការចំណាយជាក់ស្តែងដែលបានកើតឡើងរហូតដល់ស្មើនឹងចំនួនទឹកប្រាក់ដែលត្រូវបានជ្រើសរើសសម្រាប់ការព្យាបាល និងវះកាត់ ការថែទាំដោយគិលានុបដ្ឋាក/យិកាមានការបណ្តុះបណ្តាល និងការសម្រាកក្នុងមន្ទីរពេទ្យដោយចាប់ផ្តើមនៅក្នុងរយៈពេល ៥២ សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទមានគ្រោះថ្នាក់ ។

## លក្ខខណ្ឌ

១. ការធានារ៉ាប់រងនេះនឹងមិនចាប់ផ្តើមឡើយ ប្រសិនបើបុព្វលាភធានារ៉ាប់រងមិនទាន់ត្រូវបានបង់ និងទទួលជាក់ស្តែងដោយក្រុមហ៊ុន ហើយគ្មានការបង់បុព្វលាភធានារ៉ាប់រងណាមួយ ត្រូវបានចាត់ទុកថាជាការបង់ប្រាក់ទៅអោយក្រុមហ៊ុនឡើយ ប្រសិនបើគ្មានទម្រង់បោះពុម្ព ឬបង្កាន់ដៃដែលត្រូវបានចុះហត្ថលេខាត្រឹមត្រូវដោយតំណាងដែលមានការអនុញ្ញាតរបស់ក្រុមហ៊ុនត្រូវបានចេញទេនោះ ។

២. បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងដល់ក្រុមហ៊ុនភ្លាមៗ ប្រសិនបើមានការផ្លាស់ប្តូរអាសយដ្ឋាន ការងារ សកម្មភាពកំសាន្ត ឬ ប្រសិនបើមានរបួស ជំងឺ ការខូចខាត ឬពិការរាងកាយ ដែលបុគ្គលត្រូវបានធានារ៉ាប់រងបានទទួលរង ព្រមទាំងជូនដំណឹងផងដែរអំពីការធានារ៉ាប់រងដទៃទៀតសម្រាប់គ្រោះថ្នាក់ ឬពិការភាព (លើកលែងតែទាក់ទងជាមួយនឹងកិច្ចសន្យាធានារ៉ាប់រងសម្រាប់រថយន្ត) ។

៣. នៅពេលដែលមានការកើតឡើងនូវគ្រោះថ្នាក់ណាមួយ ដែលអាចធ្វើអោយមានការកើតឡើងនូវការទាមទារសំណង យោងតាមកិច្ចសន្យានេះ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងដល់ក្រុមហ៊ុនក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីមានការកើតឡើងនូវគ្រោះថ្នាក់ រួមជាមួយនឹងសេចក្តីលម្អិតនៃគ្រោះថ្នាក់ និងរបួស និងត្រូវស្នើសុំ និងអនុវត្តតាមយោបល់វេជ្ជសាស្ត្រ និងសល្យសាស្ត្រដែលត្រឹមត្រូវអោយបានឆាប់រហ័សបំផុត ។

៤. បុគ្គលដែលត្រូវបានធានារ៉ាប់រង (ឬតំណាងផ្ទាល់ខ្លួនមានការអនុញ្ញាតពីបុគ្គលដែលត្រូវបានធានារ៉ាប់រង) មានតួនាទីត្រូវផ្តល់ជូនក្រុមហ៊ុននូវលិខិតបញ្ជាក់ផ្សេងៗព័ត៌មាន និងភ័ស្តុតាងទាំងអស់ដែលអាចត្រូវបានទាមទារដោយក្រុមហ៊ុន ហើយបុគ្គលដែលត្រូវបានធានារ៉ាប់រង តម្រូវអោយផ្ញើជូនក្រុមហ៊ុននូវលទ្ធផលពិនិត្យសុខភាព ។ ក្នុងករណីបុគ្គលដែលត្រូវធានារ៉ាប់រងទទួលមរណភាព ក្រុមហ៊ុនមានសិទ្ធិធ្វើកោសល្យវិច័្ឆយក្រោយពេលស្លាប់ក្រោមការចំណាយរបស់ក្រុមហ៊ុន ហើយប្រសិនបើអាចធ្វើទៅបានត្រូវជូនដំណឹងដល់ក្រុមហ៊ុនមុនពេលបញ្ចុះ ឬបូជាសពដោយបញ្ជាក់អំពីពេលវេលា និងទីកន្លែងនៃការស៊ើបអង្កេតដែលបានកំណត់ ។

៥. រាល់ការជូនដំណឹងដែលតម្រូវអោយបុគ្គលដែលត្រូវបានធានារ៉ាប់រងផ្តល់ដល់ក្រុមហ៊ុន ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរដោយចុះអាសយដ្ឋានរបស់សាខាក្នុងមូលដ្ឋាន ឬទីភ្នាក់ងារដែលនៅជិតបំផុតរបស់ក្រុមហ៊ុន ហើយគ្មានការផ្លាស់ប្តូរណាមួយចំពោះលក្ខខណ្ឌនៅក្នុងកិច្ចសន្យានេះ ឬគ្មានការអនុម័តណាមួយចំពោះការផ្លាស់ប្តូរនេះនឹងមានសុពលភាពឡើយ ប្រសិនបើការផ្លាស់ប្តូរ ឬការអនុម័តនេះមិនត្រូវបានចុះហត្ថលេខា ឬចុះអាទិសង្កេតដោយតំណាងមានការអនុញ្ញាតពីក្រុមហ៊ុន ។

៦. លើកលែងតែត្រូវបានបញ្ជាក់ច្បាស់លាស់ផ្សេងពីនេះ តាមរយៈការអនុម័តលើកិច្ចសន្យានេះ ក្រុមហ៊ុនត្រូវមានសិទ្ធិចាត់ទុកបុគ្គលដែលត្រូវបានធានារ៉ាប់រងថាជាម្ចាស់តែមួយគត់នៃកិច្ចសន្យានេះ ហើយក្រុមហ៊ុនមិនត្រូវបានតម្រូវអោយទទួលស្គាល់នូវការទាមទារសមធម៌ ឬការទាមទារដទៃទៀត ឬអត្ថប្រយោជន៍នៅក្នុងកិច្ចសន្យានេះទេ ហើយបង្កាន់ដៃរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង (ឬតំណាងផ្ទាល់ខ្លួនមានការអនុញ្ញាតពីបុគ្គលដែលត្រូវបានធានារ៉ាប់រង) តែមួយគត់នឹងត្រូវទូទាត់ប្រកបដោយសុពលភាព ។

៧. ប្រសិនបើសំណើ ឬសេចក្តីប្រកាសរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងមានភាពមិនពិតប្រាកដដោយប្រការណាមួយ ឬប្រសិនបើកត្តាជាក់ស្តែងណាមួយដែលនាំអោយមានហានិភ័យត្រូវបានលើកឡើងដោយមិនត្រឹមត្រូវ ឬត្រូវបានលុបចេញ ឬប្រសិនបើការធានារ៉ាប់រងនេះ ឬការបន្តការធានារ៉ាប់រងនេះត្រូវបានធ្វើឡើងដោយសារការប្រកាសមិនពិត ការអះអាងមិនពិត ឬការលាក់បាំង ឬប្រសិនបើការទាមទារសំណងដែលត្រូវបានធ្វើឡើងមានលក្ខណៈក្លែងបន្លំ ឬបំផ្លើស ឬប្រសិនបើការប្រកាស ឬការបញ្ជាក់ក្លែងក្លាយ ត្រូវបានធ្វើឡើងដើម្បីគាំទ្រដល់សំណើ ឬសេចក្តីប្រកាស ពេលនោះទោះជាក្នុងករណីណាមួយក៏ដោយក្នុងចំណោមករណីទាំងនេះ កិច្ចសន្យានេះនឹងត្រូវបានចាត់ទុកជាមោឃៈ ។

៨. កិច្ចសន្យាធានារ៉ាប់រងនេះ អាចត្រូវបានបញ្ចប់តាមការស្នើសុំរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រុមហ៊ុនក្នុងរយៈពេល ១០ថ្ងៃ ដោយក្នុងករណីនេះក្រុមហ៊ុននឹងបង់ជូនចំនួន ៩០% នៃអត្រាសមមាត្រនៃបុព្វលាភធានារ៉ាប់រងសំរាប់រយៈពេលនៃការធានារ៉ាប់រងដែលមិនទាន់ផុតកំណត់ ដោយគិតចាប់ពីថ្ងៃមោឃភាពនៃកិច្ចសន្យា និងដោយហេតុថាពុំមានបណ្តឹងទាមទារសំណងកើតឡើងក្នុងរយៈពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះស្ថិតនៅមានសុពលភាព ។ កិច្ចសន្យាធានារ៉ាប់រងនេះអាចត្រូវបានបញ្ចប់ផងដែរ ដោយជម្រើសរបស់ក្រុមហ៊ុន តាមរយៈការជូនដំណឹងក្នុងរយៈពេល ១០ថ្ងៃ តាមលិខិតអនុសិដ្ឋិទៅកាន់អាសយដ្ឋានចុងក្រោយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ក្នុងករណីនេះក្រុមហ៊ុនមានកាតព្វកិច្ចបង់ជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវបុព្វលាភធានារ៉ាប់រងតាមអត្រាសមាមាត្រសំរាប់រយៈពេលដែលមិនទាន់ផុតកំណត់ គិតចាប់ពីថ្ងៃមោឃភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះ ។

រាល់ការសុំបញ្ឈប់ការធានារ៉ាប់រង លោកអ្នកនឹងមិនត្រូវបានទទួលការបង្វិលសងនូវបុព្វលាភធានារ៉ាប់រងវិញឡើយ ប្រសិនបើបុព្វលាភនោះត្រូវបានបង់ក្នុងកម្រិតអប្បបរមា។

៩. ប្រសិនបើមានវិវាទកើតឡើងទាក់ទងនឹងទឹកប្រាក់ដែលត្រូវបង់នៅក្នុងកិច្ចសន្យានេះ (សំណងត្រូវបានទទួលស្គាល់ដោយក្រុមហ៊ុន) វិវាទនេះត្រូវបានបញ្ជូនទៅដោះស្រាយដោយមជ្ឈត្តករមួយរូបដែលត្រូវតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីវិវាទ ឬប្រសិនបើពួកគេមិនអាចឯកភាពគ្នាអោយមានមជ្ឈត្តករតែមួយរូប ត្រូវបញ្ជូនទៅដោះស្រាយដោយមជ្ឈត្តករពីររូប ដែលមជ្ឈត្តករមួយរូបត្រូវតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីនីមួយៗ ក្នុងរយៈពេលមួយខែនៃប្រតិទិនបន្ទាប់ពីត្រូវបានទាមទារជាលាយលក្ខណ៍អក្សរអោយធ្វើដូច្នេះដោយភាគីនីមួយៗ ឬ ក្នុងករណីមជ្ឈត្តករទាំងពីរមិនព្រមព្រៀងគ្នា ត្រូវបញ្ជូនទៅដោះស្រាយដោយប្រធានក្រុមប្រឹក្សាមជ្ឈត្តករដែលត្រូវតែងតាំងជាលាយលក្ខណ៍អក្សរដោយមជ្ឈត្តករទាំងពីរមុនពេលចាប់ផ្តើមធ្វើការពិចារណា ។ ប្រធានក្រុមប្រឹក្សាមជ្ឈត្តករត្រូវអង្គុយនៅជាមួយមជ្ឈត្តករទាំងពីរ និងធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ពួកគេ ។ រាល់ការធ្វើសេចក្តីសម្រេចគឺជាបុរេលក្ខខណ្ឌនៃសិទ្ធិប្តឹងជំទាស់នឹងក្រុមហ៊ុន ។

១០. ទោះជាក្នុងករណីណាក៏ដោយ ក្រុមហ៊ុននឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាត បន្ទាប់ពីផុតរយៈពេលដប់ពីរ (១២) ខែ ដោយគិតចាប់ពីពេលមានការកើតឡើងនូវការបាត់បង់ ឬការខូចខាតឡើយ លើកលែងតែការទាមទារគឺជាកម្មវត្ថុនៃបណ្តឹង កំពុងវិនិច្ឆ័យ ឬមជ្ឈត្តការ ។

១១. ការគោរពប្រតិបត្តិ និងការបំពេញតាម ខ លក្ខខណ្ឌ និងបដិលេខនៃកិច្ចសន្យានេះក្នុងកម្រិតដែលវាពាក់ព័ន្ធនឹងអ្វីមួយដែលត្រូវធ្វើ ឬគោរពតាមដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង និងការពិតនៃសេចក្តីប្រកាស និងចម្លើយនៅក្នុងកម្រងសំណួរសំណើ និងការប្រកាសប្រចាំខែដែលធ្វើឡើងដោយបុគ្គលដែលត្រូវធានារ៉ាប់រង គឺជាបុរេលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនដែលត្រូវធ្វើការបង់សំណងយោងតាមកិច្ចសន្យានេះ ។

**១២. លក្ខខណ្ឌបុព្វលាភធានារ៉ាប់រង**

លក្ខខណ្ឌពិសេសជាមូលដ្ឋាន និងតែមួយគត់នៃកិច្ចសន្យាធានារ៉ាប់រងនេះ តម្រូវថាបុព្វលាភធានារ៉ាប់រងដែលដល់ពេលត្រូវបង់ ត្រូវតែបង់ និងទទួលដោយក្រុមហ៊ុនក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមកិច្ចសន្យានេះ/ បដិលេខ/លិខិតបញ្ជាក់អំពីការបន្តកិច្ចសន្យា ។

ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពតាមទេនោះ កិច្ចសន្យានេះនឹងត្រូវបានចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនមានសិទ្ធិទទួលបានបុព្វលាភធានារ៉ាប់រងតាមសមាមាត្រនៃរយៈពេលដែលខ្លួនស្ថិតនៅក្នុងហានិភ័យ។

នៅពេលដែលបុព្វលាភធានារ៉ាប់រងដែលត្រូវបង់យោងតាមការធានានេះត្រូវបានទទួលដោយភ្នាក់ងារមានការអនុញ្ញាតពីក្រុមហ៊ុន នោះការបង់ប្រាក់នឹងត្រូវបានចាត់ទុកថាត្រូវបានទទួលដោយក្រុមហ៊ុនសម្រាប់គោលបំណងនៃការធានានេះ ហើយកាតព្វកិច្ចក្នុងការបង្ហាញថាបុព្វលាភធានារ៉ាប់រងដែលត្រូវបង់នោះត្រូវបានទទួលដោយបុគ្គលម្នាក់ រួមទាំងភ្នាក់ងារធានារ៉ាប់រងផងដែរ ហើយសំរាប់បុគ្គលដែលមិនមានសិទ្ធិទទួលបុព្វលាភធានារ៉ាប់រង គឺជាសិទ្ធិសម្រេចរបស់ក្រុមហ៊ុន។

រាល់ ខ ចែង និងលក្ខខណ្ឌទាំងអស់ត្រូវយោងលើកិច្ចសន្យាធានារ៉ាប់រងនេះ ។

ទំព័រនេះត្រូវបានទុកចោលដោយចេតនា